ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ២៤ កយ.សសរ/២១

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារចំពោះកិច្ចសិក្សាស្រាវជ្រាវកម្មវិធីសិក្សា របស់សាលាតូមិនួចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៥/០១៩ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥ ស្តីពីការបង្កើតរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៥៨ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការផ្ទេររាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមតម្រូវការចាំបាច់របស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ KR

## **សម្រេច**

**ប្រការ១**.-

បង្កើតក្រុមការងារចំពោះកិច្ចសិក្សាស្រាវជ្រាវកម្មវិធីសិក្សារបស់សាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ដែលមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១-ឯកឧត្តម **គេង សុម៉ារិទ្ធ** | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិតវេជ្ជ **ឈុន ព្រលឹង** | អនុប្រធាន |
| ៣-ឯកឧត្តមបណ្ឌិត **ឆាយ ហុកផេង** | អនុប្រធាន |
| ៤-ឯកឧត្តម **នាក់ សើគីរ៉េន** | សមាជិក |
| ៥-ឯកឧត្តម **សន សោភ័ណ** | សមាជិក |
| ៦-ឯកឧត្តម **យឹម សារី** | សមាជិក |
| ៧-ឯកឧត្តម **ប៉ែន ពេជ្រសាលី** | សមាជិក |
| ៨-ឯកឧត្តម **តាន់ហ៊ាង ដាវ័ណ្ណា** | សមាជិក |
| ៩-ឯកឧត្តម **សេង នាង** | សមាជិក |
| ១០-ឯកឧត្តម **ច័ន្ទ រះឡើ** | សមាជិក |
| ១១-ឯកឧត្តម **ម្លង់ សំណាង** | សមាជិក |
| ១២-លោក **សេង លាង** | សមាជិក |
| ១៣-លោក **ម្លង់ សុផល** | សមាជិក |
| ១៤-លោកស្រី **ឌី ម៉ូឡានី** | លេខាធិការ |
| ១៥-លោក **ជៀប សេងហួរ** | លេខាធិការ។ |

**ប្រការ២**.-

ក្រុមការងារចំពោះកិច្ចសិក្សាស្រាវជ្រាវកម្មវិធីសិក្សារបស់សាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានភារកិច្ចដូចខាងក្រោម៖

- សិក្សា ស្រាវជ្រាវ កែសម្រួល និងធ្វើបច្ចុប្បន្នកម្មកម្មវិធីសិក្សារបស់សាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ សំដៅធានាបាននូវគុណភាព ប្រសិទ្ធភាព និងធ្វើឱ្យមានទំនើបកម្មនៃការបណ្តុះបណ្តាលវិជ្ជាជីវៈចៅក្រម

- រៀបចំកម្មវិធីសិក្សាសម្រាប់សិស្សចៅក្រមទៅតាមជំនាន់នីមួយៗ ដែលត្រូវបានជ្រើសរើសរួចជាផ្លូវការ

- សិក្សា ស្រាវជ្រាវ និងរៀបចំកម្មវិធីសិក្ខាសាលា សន្និសីទ បទបាឋកថា ទស្សនកិច្ចសិក្សា វគ្គបណ្តុះបណ្តាលខ្លី ឬវែង វគ្គបណ្តុះបណ្តាលបន្ត និងវិក្រឹតការ សម្រាប់ចៅក្រម ព្រះរាជអាជ្ញា ដែលកំពុងបំពេញការីយកម្មនៅតាមសាលាជម្រះក្តី KR

- ពិភាក្សា និងពិគ្រោះយោបល់ជាមួយអ្នកជំនាញការជាតិ និងអន្តរជាតិ ដើម្បីប្រមូលធាតុចូលសម្រាប់ធ្វើការកែសម្រួល និងធ្វើបច្ចុប្បន្នកម្មកម្មវិធីសិក្សារបស់សាលាភូមិន្ទថៅក្រម
- ធ្វើរបាយការណ៍អំពីវឌ្ឍនភាពការងារដើម្បីសុំយោបល់ ឬការសម្រេចពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- បំពេញភារកិច្ចផ្សេងៗទៀត តាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ប្រការ៣ .-**

អនុប្រធាន និងសមាជិកក្រុមការងារចំពោះកិច្ចសិក្សាស្រាវជ្រាវកម្មវិធីសិក្សារបស់សាលាភូមិន្ទថៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ អនុប្រធានអាចកោះប្រជុំ និង/ឬ ដឹកនាំកិច្ចប្រជុំជំនួសបាន តាមការប្រគល់សិទ្ធិពីប្រធាន។

ក្រុមការងារចំពោះកិច្ចសិក្សាស្រាវជ្រាវកម្មវិធីសិក្សារបស់សាលាភូមិន្ទថៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ អាចអញ្ជើញមន្ត្រីជំនាញពីបណ្ដាក្រសួង ស្ថាប័នជាតិ ស្ថាប័នអន្តរជាតិ និងវិស័យឯកជនចូលរួមប្រជុំពិគ្រោះយោបល់តាមការចាំបាច់។

**ប្រការ៤ .-**

ក្រុមការងារចំពោះកិច្ចសិក្សាស្រាវជ្រាវកម្មវិធីសិក្សារបស់សាលាភូមិន្ទថៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ប្រើប្រាស់ទីតាំងរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ សម្រាប់កិច្ចដំណើរការការងាររបស់ខ្លួន។

**ប្រការ៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

នាយកខុទ្ទកាល័យ ប្រធានរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការតុលាការ ប្រធានគ្រប់អង្គភាពក្រោមឱវាទនៃក្រសួងយុត្តិធម៌និងរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ២រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**កើត រិទ្ធ**

**កន្លែងទទួល ៖**
- ដូចប្រការ៦
- ឯកសារ កាលប្បវត្តិ